**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១៩/១០២៤ ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២០អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើត **"អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា"** ហៅកាត់ថា **"អគ្គលេខាធិការដ្ឋាន គ.ជ.ផ.ក."** ដែលជាសេនាធិការផ្នែកបច្ចេកទេស និងរដ្ឋបាលសម្រាប់គាំទ្រការបំពេញតួនាទី ភារកិច្ច បេសកកម្ម គោលបំណង និងគោលដៅរបស់ **គ.ជ.ផ.ក.** ដើម្បីសម្រេចឱ្យបានផលិតភាពសេដ្ឋកិច្ច និងបង្កើនភាពជាម្ចាស់នៃសេដ្ឋកិច្ចជាតិ ក៏ដូចជាលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ។

## ជំពូកទី២

## មុខងារ និងតួនាទី

**មាត្រា២.-**

អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** មានមុខងារ និងតួនាទី ដូចតទៅ÷

- សិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រក្នុងក្របខណ្ឌផលិតភាពសេដ្ឋកិច្ច ជូន **គ.ជ.ផ.ក.**
- គាំទ្រការរៀបចំ និងបង្កើតគោលនយោបាយក្នុងក្របខណ្ឌផលិតភាពសេដ្ឋកិច្ច ដើម្បីសម្រេចបានផលិតភាពជាតិសរុប និងភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ ជូន **គ.ជ.ផ.ក.**
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើកំណើន និងនិន្នាការផលិតភាពសេដ្ឋកិច្ចជាតិ សម្រាប់រាយការណ៍ជូន **គ.ជ.ផ.ក.**
- ផ្តល់អនុសាសន៍ ទិសដៅ ជម្រើស និងយុទ្ធសាស្ត្រគោលនយោបាយជូន **គ.ជ.ផ.ក.**
- អនុវត្តយុទ្ធសាស្ត្រ និងយន្តការសហប្រតិបត្តិការអន្តរក្រសួងស្ថាប័ន ដើម្បីគាំទ្រគោលបំណង និងគោលដៅរបស់ **គ.ជ.ផ.ក.**
- ជំរុញប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការគ្រប់គ្រងប្រតិបត្តិការរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.**
- សម្របសម្រួល និងអនុវត្តការងាររដ្ឋបាលប្រចាំថ្ងៃ ដើម្បីគាំទ្រការបំពេញការងារជូន **គ.ជ.ផ.ក.**
- បំពេញភារកិច្ចផ្សេងទៀត តាមការប្រគល់ជូនរបស់ប្រធាន **គ.ជ.ផ.ក.**។

**មាត្រា៣.-**

អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** មានសិទ្ធិអញ្ជើញមន្ត្រីបច្ចេកទេសនៃក្រសួងស្ថាប័ន និងដៃគូពាក់ព័ន្ធចូលរួមកិច្ចប្រជុំ ដើម្បីបំភ្លឺបញ្ហានានា ប្រមូលធាតុចូល ព័ត៌មាន និងទិន្នន័យ តាមការចាំបាច់ និងជាក់ស្តែង សម្រាប់ទ្រទ្រង់ដល់ការបំពេញតួនាទី និងភារកិច្ចរបស់ **គ.ជ.ផ.ក.**។

## ជំពូកទី៣

## រចនាសម្ព័ន្ធគាំទ្រ

**មាត្រា៤.-**

អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** ត្រូវដឹកនាំដោយអគ្គលេខាធិការ ១(មួយ)រូប និងអគ្គលេខាធិការរង ២(ពីរ)រូប។



អគ្គលេខាធិការ **គ.ជ.ផ.ក.** ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ និងអគ្គលេខាធិការរង **គ.ជ.ផ.ក.** ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់ប្រធាន **គ.ជ.ផ.ក.**។

អគ្គលេខាធិការ និងអគ្គលេខាធិការរង **គ.ជ.ផ.ក.** ត្រូវតែងតាំងក្នុងចំណោមមន្ត្រីមុខងារសាធារណៈ ដែលមានក្របខណ្ឌនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា៥.-**

អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** អាចមានទីប្រឹក្សា មន្ត្រី ឬបុគ្គលិក ដែលជាមន្ត្រីក្របខណ្ឌមុខងារសាធារណៈ ឬបុគ្គលិកកិច្ចសន្យាខាងក្រៅ ដើម្បីជួយបំពេញការងាររបស់ខ្លួន ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** អាចជ្រើសរើសមន្ត្រីមុខងារសាធារណៈឱ្យបំពេញការងារនៅក្នុងអគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមនីតិវិធីជាធរមាន។

អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** អាចជ្រើសរើសមន្ត្រីមុខងារសាធារណៈពីក្រសួងស្ថាប័នដទៃឱ្យមកបំពេញការងារនៅអគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** បន្ទាប់ពីមានការឯកភាពពីប្រធានស្ថាប័នសាមី។ មន្ត្រីទាំងនោះត្រូវដាក់ឱ្យស្ថិតនៅក្រៅក្របខណ្ឌដើម និងត្រូវបំពេញការងារពេញម៉ោងនៅអគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.**។

មន្ត្រីរាជការដែលត្រូវបានជ្រើសរើសឱ្យបំពេញការងារនៅអគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** ត្រូវរក្សាទុកប្រាក់បៀវត្សប្រាក់វិភាជន៍គ្រួសារ និងអតីតភាពការងារនៅអង្គភាពដើម ក្នុងពេលបំពេញការងារនៅអគ្គលេខាធិការដ្ឋាន**គ.ជ.ផ.ក.**។

នៅពេលបញ្ចប់មុខតំណែងនៅអគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** មន្ត្រីសាមីត្រូវរាយការណ៍ចូលបម្រើការងារក្នុងក្របខណ្ឌដើមវិញ ដោយទទួលបានឋានន្តរសក្តិ និងប្រាក់បំណាច់មុខងារ ដែលមានមុនពេលតែងតាំងចូលបំពេញការងារនៅអគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.**។ មន្ត្រីសាមីនឹងទទួលបានសិទ្ធិអាទិភាពលើការតែងតាំងចូលបំពេញការងារក្នុងមុខតំណែងដើម ឬមុខតំណែងទំនេរដែលប្រហាក់ប្រហែលនឹងមុខតំណែងដើម ផ្អែកតាមរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួងស្ថាប័ន និងការសម្រេចរបស់ប្រធានស្ថាប័ន។

**មាត្រា៦.-**

អគ្គលេខាធិការ អគ្គលេខាធិការរង ប្រធានផ្នែក ទីប្រឹក្សា មន្ត្រី និងបុគ្គលិកកិច្ចសន្យា ដែលបំពេញការងារនៅអគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** ត្រូវមានគុណវឌ្ឍិ ចំណេះដឹង សមត្ថភាព ជំនាញវិជ្ជាជីវៈ និងការទទួលខុសត្រូវខ្ពស់ ហើយត្រូវអនុវត្តការងារដោយផ្អែកលើគោលការណ៍ផលិតភាព និងសមិទ្ធផលការងារជាក់ស្តែង។

**មាត្រា៧.-**

អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** មានរចនាសម្ព័ន្ធគាំទ្រចំនួន បីផ្នែករួមមាន÷

- ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ
- ផ្នែកបច្ចេកទេសសិក្សាស្រាវជ្រាវ
- ផ្នែកគ្រប់គ្រង និងសន្ទានកម្មទិន្នន័យ

ផ្នែកនីមួយៗ ត្រូវដឹកនាំដោយប្រធាន ១(មួយ)រូប ដែលនឹងត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.ផ.ក.**។

រចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៨.-**

ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ មានតួនាទី និងភារកិច្ច ដូចតទៅ÷

- សម្របសម្រួលការងារប្រចាំថ្ងៃរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.**
- សម្របសម្រួល និងសហប្រតិបត្តិការជាមួយក្រសួងស្ថាប័ន និងដៃគូពាក់ព័ន្ធ ទាំងកម្រិតជាតិ និងអន្តរជាតិ
- រៀបចំកិច្ចប្រជុំ សិក្ខាសាលា សន្និសីទ និងកិច្ចពិគ្រោះយោបល់នានា ជូនអគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** និង **គ.ជ.ផ.ក.**
- រៀបចំ ចាត់ចែង និងធ្វើរបាយការណ៍កិច្ចប្រជុំ របស់អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** និង **គ.ជ.ផ.ក.**
- រៀបចំរបាយការណ៍ស្តីពីសកម្មភាពរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** ជូនប្រធាន **គ.ជ.ផ.ក.**
- គ្រប់គ្រង រៀបចំ និងចាត់ចែងគណនេយ្យ និងហិរញ្ញវត្ថុរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.**
- គ្រប់គ្រងសម្ភារៈការិយាល័យ សម្ភារបរិក្ខារៈ និងសន្និធិរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.**
- គ្រប់គ្រងធនធានមនុស្សរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.**
- រៀបចំ និងគ្រប់គ្រងឡូជីស្ទីក របស់អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.**
- បំពេញការងារផ្សេងទៀតតាមការប្រគល់ជូនពីអគ្គលេខាធិការ **គ.ជ.ផ.ក.**។

**មាត្រា៩.-**

ផ្នែកបច្ចេកទេសសិក្សាស្រាវជ្រាវ មានតួនាទី និងភារកិច្ច ដូចតទៅ÷

- គ្រប់គ្រង និងអភិវឌ្ឍកម្មវិធីសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រ
- រៀបចំ និងរចនាគម្រោងសិក្សាស្រាវជ្រាវ
- គាំទ្រការរៀបចំ បង្កើតគោលនយោបាយ និងយុទ្ធសាស្ត្រគោលនយោបាយក្នុងក្របខណ្ឌផលិតភាពសេដ្ឋកិច្ច និងភាពប្រកួតប្រជែង ជូនអគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** និង **គ.ជ.ផ.ក.**
- អនុវត្តកិច្ចការត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើគោលនយោបាយពាក់ព័ន្ធនឹងផលិតភាពជាតិ និងភាពប្រកួតប្រជែង ដើម្បីរាយការណ៍ជូនអគ្គលេខាធិការ **គ.ជ.ផ.ក.** និង **គ.ជ.ផ.ក.**
- រៀបចំជម្រើសគំរូគោលនយោបាយ ដើម្បីជំរុញផលិតភាពសេដ្ឋកិច្ច និងភាពប្រកួតប្រជែង
- ផ្តល់អនុសាសន៍ និងយុទ្ធសាស្ត្រគោលនយោបាយ ក្នុងក្របខណ្ឌផលិតភាពសេដ្ឋកិច្ច និងភាពប្រកួតប្រជែង ជូនអគ្គលេខាធិការ **គ.ជ.ផ.ក.** និង **គ.ជ.ផ.ក.**
- បំពេញការងារផ្សេងទៀតតាមការប្រគល់ជូនពីអគ្គលេខាធិការ **គ.ជ.ផ.ក.**។

**មាត្រា១០.-**

ផ្នែកគ្រប់គ្រង និងសន្ទានកម្មទិន្នន័យ មានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- បង្កើត និងអនុវត្តកម្មវិធីវិទ្យាសាស្ត្រទិន្នន័យ
- រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងព័ត៌មាន ដើម្បីត្រួតពិនិត្យ តាមដាន និងវាយតម្លៃសមិទ្ធផលនៃគោលនយោបាយពាក់ព័ន្ធនឹងផលិតភាពសេដ្ឋកិច្ច និងភាពប្រកួតប្រជែង
- រៀបចំ ផ្សព្វផ្សាយ និងចែករំលែកចំណេះដឹងជូនសាធារណៈ ក្នុងក្របខណ្ឌផលិតភាពសេដ្ឋកិច្ច និងភាពប្រកួតប្រជែង
- បំពេញការងារផ្សេងទៀតតាមការប្រគល់ជូនពីអគ្គលេខាធិការ **គ.ជ.ផ.ក.**។

**មាត្រា១១.-**

អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** មានប្រភពធនធានថវិកាផ្គត់ផ្គង់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិដែលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការ ជាតិនិងអន្តរជាតិ និងពីប្រភពស្របច្បាប់ផ្សេងៗទៀត។



## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា១២.-**

សេចក្តីសម្រេចលេខ ១៦០ សសរ. ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបង្កើតលេខាធិការដ្ឋានគណៈកម្មាធិការផលិតភាពកម្ពុជា ត្រូវទុកជានិរាករណ៍។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ១៥កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមីនា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១៣
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ